# កញ្ចប់ជំនួយសង្គ្រោះបន្ទាន់

Emergency relief packages - Khmer

កញ្ចប់ជំនួយសង្គ្រោះស្បៀងអាហារបន្ទាន់ឥតគិតថ្លៃមានផ្តល់ជូន ប្រសិនបើអ្នកមិនអាចរកបានម្ហូបអាហារដោយសារមានវីរុសកូរ៉ូណា (ជំងឺកូវីដ-១៩)។

អ្នកមិនចាំបាច់ជាពលរដ្ឋអូស្ត្រាលី ឬអ្នករស់នៅជាអចិន្ត្រៃយ៍ឡើយដើម្បីទទួលបានកញ្ចប់ជំនួយសង្គ្រោះបន្ទាន់។

ដើម្បីទទួលបានកញ្ចប់ជំនួយសង្គ្រោះស្បៀងអាហារបន្ទាន់ អ្នកត្រូវតែះ

- ស្ថិតនៅក្នុងភាពដាក់ខ្លួនឱ្យនៅដាច់ពីគេ ឬដាក់ឱ្យនៅដាច់ដោយឡែកពីគេ ពីព្រោះតែអ្នកមានវីរុសកូរ៉ូណា កំពុងរង់ចាំលទ្ធផលតេស្ត ឬជាអ្នកមានទំនាក់ទំនងជិតស្និទ្ធ
- មិនមានមិត្តភក្តិ ក្រុមគ្រួសារ ឬមនុស្សផ្សេងទៀតដែលអាចជួយអ្នកបាន។

ដើម្បីទទួលបានកញ្ចប់ សូមទូរស័ព្ទទៅខ្សែទូរស័ព្ទទាន់ហេតុការណ៍ស្តីពីវីរុសកូរ៉ូណាលេខ **1800 675 398** ហើយជ្រើសរើសជម្រើសសម្រាប់ការគាំទ្រអ្នកដែលមានវីរុសកូរ៉ូណា (នេះរួមបញ្ចូលទាំងជំនួយសង្គ្រោះស្បៀងអាហារ)។ ប្រសិនបើអ្នកត្រូវការអ្នកបកប្រែភាសា សូមជ្រើសរើសជម្រើសលេខ 0 ពេលណាអ្នកទូរស័ព្ទទៅខ្សែទូរស័ព្ទទាន់ហេតុការណ៍។

ប្រសិនបើអ្នកមិនអាចទូរស័ព្ទទៅខ្សែទូរស័ព្ទទាន់ហេតុការណ៍ដោយខ្លួនឯងទេ នរណាម្នាក់ដែលអ្នកស្គាល់អាចទូរស័ព្ទជូនអ្នកបាន។

អ្នកក៏អាចទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុផងដែរ ប្រសិនបើអ្នកចាំបាច់ត្រូវខកខានមិនទៅធ្វើការងារ។ សម្រាប់ព័ត៌មានបន្ថែម សូមទូរស័ព្ទទៅខ្សែទូរស័ព្ទទាន់ហេតុការណ៍ស្តីពីវីរុសកូរ៉ូណា។

## តើមានអ្វីខ្លះនៅក្នុងកញ្ចប់?

នៅក្នុងកញ្ចប់មានអាហារចាំបាច់ដូចជាធញ្ញជាតិ ទឹកដោះគោទុកបានយូរ ស្ករ ប៉ាស្តា និងបន្លែកំប៉ុង។ វាក៏មានរបស់របរផ្ទាល់ខ្លួនផងដែរដូចជាសាប៊ូ ថ្នាំបំបាត់ក្លិនអាក្រក់ និងថ្នាំដុសធ្មេញ។ ប្រសិនបើអ្នកត្រូវការ អ្នកក៏អាចទទួលបានកន្ទបទារក និងម្សៅទឹកដោះគោសម្រាប់ទារកផងដែរ។

កញ្ចប់ទាំងនេះគឺឥតគិតថ្លៃ ហើយនឹងផ្តល់ឱ្យអ្នកនូវអាហារចាំបាច់ និងរបស់របរផ្ទាល់ខ្លួនគ្រប់គ្រាន់សម្រាប់រយៈពេលពីរសប្តាហ៍។ អ្នកនឹងទទួលបានអាហារ និងរបស់របរផ្សេងទៀតគ្រប់គ្រាន់សម្រាប់ខ្លួនអ្នក និងអ្នកផ្សេងទៀតដែលអ្នករស់នៅជាមួយ។

### អាហារ

ប្រសិនបើអ្នកឈឺខ្លាំង ឬមិនអាចចម្អិនអាហារបានដោយខ្លួនឯងទេ អ្នកប្រហែលជាអាចនឹងទទួលបានអាហារដឹកជូនដល់ផ្ទះ។ នៅពេលអ្នកទូរស័ព្ទទៅខ្សែទូរស័ព្ទទាន់ហេតុការណ៍ ព័ត៌មានលម្អិតរបស់អ្នកនឹងត្រូវបានផ្តល់ឱ្យសាលាក្រុងរបស់អ្នក ហើយពួកគេនឹងទាក់ទងមកអ្នកអំពីជម្រើសគាំទ្រ។

## តើខ្ញុំនឹងទទួលបានកញ្ចប់ដោយរបៀបណា?

កញ្ចប់នោះនឹងត្រូវបានទុកនៅមាត់ទ្វារផ្ទះរបស់អ្នក ដើម្បីឱ្យអ្នកទៅយក។

To receive this publication in a different format email covid-19@dhhs.vic.gov.au <covid-19@dhhs.vic.gov.au>.

Authorised and published by the Victorian Government, 1 Treasury Place, Melbourne.

© State of Victoria, Australia, Department of Health and Human Services, 27 August 2020.

Available at DHHS.vic –Translated resources - coronavirus (COVID-19) <https://www.dhhs.vic.gov.au/translated-resources-coronavirus-disease-covid-19>

Emergency Relief Packages - Khmer

OFFICIAL